*គុណតម្លៃ*

*ការប្តេជ្ញាចិត្ត តម្លាភាព ភក្តីភាព យ សេចក្តីសុចរិត និង ភាពជាអ្នកបំរើ យជីវិតបានប្រសើរឡើង។*

*ទស្សនៈវិស័យ*

*ប្រជាពលរដ្ឋមានទឹកប្រើប្រាស់សុខភាពអនាម័ និងបរិស្ថានល្អដើម្បីអោ*

# ការពិពណ៌នាការងារ

**បេសកកម្ម:** *លើកកំពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាលសហគមន៍ គោលដៅដោយ ប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។*

## ១. ការសង្ខេបពីមុខតំណែង:

| | |
|---|---|
| **មុខតំនែងនៃការងារ:** | បុគ្គលិកស្ម័គ្រចិត្តផ្នែកត្រួតពិនិត្យចម្រោះទឹក |
| **ទីកន្លែង:** | **ខេត្តកំពង់ធំ** |
| **ខ្សែរយៈ និង បណ្តាញរាយការណ៍** | • ត្រូវរាយការណ៍ទៅ ៖ ប្រធានក្រុមផ្នែកត្រួតពិនិត្យចម្រោះទឹក។<br>• ធ្វើការទំនាក់ទំនងជាប្រចាំជាមួយអ្នកទទួលផលក្នុងសហគមន៍ មេភូមិ អ្នកស្ម័គ្រចិត្តភូមិ និងប្រធានក្រុមផ្នែកត្រួតពិនិត្យចម្រោះទឹក ប្រធានគម្រោងកម្មវិធីប្រចាំតំបន់នីមួយៗ បុគ្គលិកក្នុងតំបន់។ |
| **គោលបំណងនៃមុខតំណែង:** | • ធ្វើការងារជាមួយគម្រោងក្នុងសហគមន៍ដើម្បីអោយមានការកើនឡើងនូវការប្រើប្រាស់ទឹកស្អាតតាមរយៈ ការស្ទង់ ការត្រួតពិនិត្យ ការវាយតម្លៃ ការដំឡើង ការបង្រៀនអំពីការប្រើប្រាស់ និងការថែទាំចម្រោះទឹក។ |

## ២. ភារកិច្ចសំខាន់ៗ

| **ការងារទទួលខុសត្រូវ** | **សកម្មភាពការងារជាក់ស្តែងត្រូវអនុវត្ត** |
|---|---|
| **ត្រួតពិនិត្យចម្រោះទឹក** | • ជំរុញនិងលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ឲ្យប្រើប្រាស់និងថែចម្រោះទឹកឲ្យបានត្រឹមត្រូវ។<br>• បង្រៀនអំពីការប្រើប្រាស់ និងថែទាំចម្រោះទឹកដល់ប្រជាពលរដ្ឋក្នុងអំឡុងពេល និងក្រោយពេលត្រួតពិនិត្យចម្រោះទឹកតាមផ្ទះ។ |
| **ដំឡើងចម្រោះតាមផ្ទះ:** | • បង្រៀនដល់ប្រជាពលរដ្ឋនូវរបៀបលាងខ្សាច់ និងត្រួតពិនិត្យការលាងខ្សាច់របស់ប្រជាពលរដ្ឋ (ដំឡើងជាថ្មី)។<br>• ដំឡើងចម្រោះទឹកជូនប្រជាពលរដ្ឋ ដែលប្រកបទៅដោយគុណភាព។<br>• បង្រៀនអ្នកស្ម័គ្រចិត្តភូមិ (ប្រសិនបើមាន) អំពីបច្ចេកទេសនៃការដំឡើងចម្រោះទឹកដែលប្រកបទៅដោយគុណភាព។<br>• បង្រៀនឡើងវិញដល់ប្រជាពលរដ្ឋអំពីរបៀបថែទាំចម្រោះទឹក ការប្រើ |

| | |
|---|---|
| | ប្រាស់ នៅពេលដែលដំឡើងចម្រោះទឹកនៅតាមផ្ទះនីមួយៗ។ |
| **ទំនាក់ទំនងក្នុងសហគមន៍** | • មានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានភូមិ/ឃុំ មន្ត្រីអភិវឌ្ឍន៍ភូមិ និងអ្នកស្ម័គ្រចិត្ត។<br>• មានទំនាក់ទំនងជាមួយក្រុមការងារ។<br>• សហប្រតិបត្តការត្រួតពិនិត្យចម្រោះទឹកនៅតាមផ្ទះប្រជាពលរដ្ឋ។ |
| **ការងារផ្សេងៗទៀត** | • ជួយដល់ការងារផ្សេងៗទៀតតាមតម្រូវការរបស់អ្នកគ្រប់គ្រង និង ប្រធានប្រចាំខេត្ត។ |

**៣. លក្ខណៈសម្បត្តិត្រូវការ**

| | |
|---|---|
| **បទពិសោធន៍** | • ធ្លាប់ធ្វើការជាមួយសហគមន៍កាន់តែប្រសើរ។ |
| **ការសិក្សាអប់រំ** | អាន និយាយ និងសរសេរភាសាខ្មែរបានល្អ។ |
| **ជំនាញៈ** | **ជំនាញបច្ចេកទេស**<br>• មានសមត្ថក្នុងការសម្របសម្រួលសហគមន៍។<br>• ធ្វើការងារដោយឯករាជម្ចាស់ការ និងមានគំនិតច្នៃប្រឌិត។<br>• មានសមត្ថភាពបង្រៀន ពន្យល់ដល់សហគមន៍ អំពីការថែទាំ និងការប្រើប្រាស់ចម្រោះទឹក ដល់ប្រជាជននៅក្នុងសហគមន៍។<br>• សរសេរបាយការណ៍។<br>• ដឹងច្បាស់អំពីភូមិសាស្រ្តក្នុងតំបន់ប្រតិបត្តិការ។ |
| **គុណសម្បត្តិផ្ទាល់ខ្លួនៈ** | • ប្តេជ្ញាគោរពតាមបេសកកម្ម និងគុណតម្លៃរបស់អង្គការស្អាតកម្ពុជា។<br>• ធ្វើការងារជាក្រុម។<br>• ចេះបត់បែន។<br>• មានឆន្ទៈក្នុងការធ្វើការងារជាមួយសហគមន៍។ |